UNITED NATIONS
CAMBODIA

# ការគាំទ្រដល់ជនមានពិការភាព និងការឆ្លើយតបចំពោះជំងឺកូវីដ ១៩
## ឯកសារព័ត៌មានទី ១៣
## ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២១

ជនមានពិការភាពនៅកម្ពុជា ជួបប្រទះបញ្ហាប្រឈមច្រើនយ៉ាង ដូចជា វិសមភាព និងការរើសអើង ក្នុងការទទួលបានសេវាអប់រំ សេវាថែទាំសុខភាព មុខរបរ និងការងារ សេវាគាំពារសង្គម សេវាយុត្តិធម៌ និងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈជាដើម។ ពួកគេក៏ងាយទទួលរងអំពើហិង្សា និងការរំលោភបំពានសិទ្ធិមនុស្សជាមូលដ្ឋានផងដែរ។ ស្ត្រី និងក្មេងស្រីមានពិការភាពជួបប្រទះនឹងការរើសអើង និងឧបសគ្គបន្ថែមទៀត នៅពេលដែលពួកគេទៅទទួលសេវា បើធៀបនឹងបុរសដែលមានពិការភាព។ បើតាមជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ ២០១៩ ប្រជាជន ៤,៩% (ស្មើនឹង៦៨៩,៥៣២ នាក់) ដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ បានរាយការណ៍ថាជួបនឹងការលំបាកមួយចំនួន ក្នុងការបំពេញមុខងារងាយៗប្រចាំថ្ងៃរបស់ពួកគេ។

ការឆ្លងរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ បង្កការគំរាមកំហែងដល់សមាជិកទាំងអស់នៅក្នុងសង្គម ប៉ុន្តែជនមានពិការភាពជាច្រើននាក់ ជួបប្រទះនឹងបញ្ហាវិសមភាព ដែលធ្វើឱ្យពួកគេរឹតតែងាយរងគ្រោះទៅទៀត។ វិសមភាពទាំងនេះដែលមានកម្រិតរឹតតែធ្ងន់ធ្ងរសម្រាប់ស្ត្រី និងក្មេងស្រីមានពិការភាព កើតឡើងដោយសារឧបសគ្គជាច្រើន ដូចជា ការមាក់ងាយ ហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយធ្វើដំណើរ និងសេវាព័ត៌មានពុំបានបង្កភាពងាយស្រួលដល់ពួកគេ និងការខ្វះគោលនយោបាយ និងសេវាសាធារណៈដែលពុំមានលក្ខណៈបរិយាបន្ន។

ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា សូមស្វាគមន៍ក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការស្តារឡើងវិញក្រោយវិបត្តិកូវីដ១៩ ដែលមានលក្ខណៈបរិយាបន្នសម្រាប់ជនមានពិការភាព។ ការអនុម័តច្បាប់ស្តីពីពិការភាពថ្មីនាពេលខាងមុខ (រំពឹងថានឹងត្រូវអនុម័ត ក្នុងឆ្នាំ ២០២២) ដែលនឹងឆ្លុះបញ្ចាំងពីអភិក្រមផ្អែកតាមសិទ្ធិ ដូចចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) នឹងដាក់ចេញនូវមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអនុវត្តសកម្មភាពនាពេលអនាគត។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (២០១៩-២០២៣ NDSP2)ក៏ផ្តល់នូវក្របខ័ណ្ឌសម្រាប់ឱ្យក្រសួងស្ថាប័ននានា ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ អនុវត្តសកម្មភាពផងដែរ។ លើសពីនេះ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ (SPPF) ដាក់ចេញនូវចក្ខុវិស័យដើម្បីពង្រីកវិសាលភាពគ្របដណ្តប់ និងបង្កើនភាពស៊ីប្រទាក់ក្រឡាគ្នានៃកម្មវិធីជំនួយសង្គម កម្មវិធីធានារ៉ាប់រងសង្គម និងកម្មវិធីទីផ្សារការងារ។

**ប្រព័ន្ធអង្គការសហប្រជាជាតិ (UN) នៅកម្ពុជា កំពុងផ្តល់ការគាំទ្រយ៉ាងសកម្ម ដល់រាជរដ្ឋាភិបាល នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាឱ្យមានឆ្លើយតបចំពោះជំងឺកូវីដ១៩ ប្រកបដោយប្រសិទ្ធភាព និងមានបរិយាបន្នពិការភាព។** ក្រៅពីវិស័យសុខាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើន កំពុងផ្តោតការយកចិត្តទុកដាក់លើផលប៉ះពាល់ដែល

បង្កឡើងដោយសារការរាតត្បាតជាសកលនេះ លើវិស័យដទៃទៀត និងកំពុងរួមចំណែកផ្តល់ការគាំទ្រតាមវិស័យមួយចំនួន ដូចជា វិស័យគាំពារសង្គម អប់រំ និងការងារ ជាដើម។

- តាមរយៈការសហការជាមួយនឹងក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការជនពិការ អង្គការសហប្រជាជាតិ បានធ្វើការវិភាគស្ថានភាពនៅក្នុងប្រទេស និងបានប៉ាន់ប្រមាណពីផលប៉ះពាល់ ដែលជំងឺកូវីដ១៩ បង្កលើសិទ្ធិ និងសុខមាលភាពរបស់ជនមានពិការភាព ព្រមទាំងបានជួយរៀបចំនូវផែនការស្តារឡើងវិញរយៈពេល ៣ ឆ្នាំ។ ការវិភាគនេះបានកំណត់ពីចំណុចខ្វះខាត និងកាលានុវត្តភាពសំខាន់ៗ ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ដែលការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ មានមកលើជនមានពិការភាព។ ផលប៉ះពាល់ទាំងនេះរួមមាន៖ ភាពក្រីក្រ និងការប្រកបមុខរបរចិញ្ចឹមជីវិតដែលពុំមានចីរភាព ការរើសអើង និងឥរិយាបថអវិជ្ជមាន អំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី និងចាស់ជរាដែលមានពិការភាព ព័ត៌មាននិងការអប់រំ ការមិនផ្តល់នូវភាពងាយស្រួលសម្រាប់ជនមានពិការភាពក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការខ្វះការផ្តល់ផាសុកវត្ថុ។
- អង្គការសហប្រជាជាតិបានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋាភិបាល ដើម្បីធានាឱ្យកម្មវិធីគាំពារសង្គម ត្រូវបានអនុវត្តប្រកបដោយសមធម៌ និងផ្តល់ភាពងាយស្រួលដល់ជនមានពិការភាព។ ជាលទ្ធផលជនមានពិការភាពប្រមាណ ៥៩,000 នាក់ បានទទួលផលពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនេះ។
- អង្គការសហប្រជាជាតិបានផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិជនមានពិការភាពដូចជា សិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយតាមរយៈការផ្តល់សេវាជំនួយផ្លូវច្បាប់ និងការកសាងសមត្ថភាពដល់តួអង្គនៅក្នុងវិស័យយុត្តិធម៌។
- ដោយឡែកសម្រាប់ផែនការឆ្លើយតប និងស្តារឡើងវិញពីជំងឺកូវីដ១៩ អង្គការសហប្រជាជាតិ និងក្រសួងអប់រំ យុវជន និងកីឡា បានបង្កភាពងាយស្រួលឱ្យកុមារមានពិការភាព អាចបន្តរៀនសូត្រ ដូចជា តាមរយៈថ្នាលអប់រំអនឡាញ ជាដើម ដោយបញ្ចូលការបកប្រែភាសាសញ្ញាទៅក្នុងឃ្លីបវីដេអូដែលប្រើប្រាស់សម្រាប់ការរៀនសូត្រ ការរៀបចំ និងផ្តល់សម្ភារៈឯកសារអប់រំដែលមានលក្ខណៈបរិយាបន្ន និងកញ្ចប់អប់រំបំប៉ន ដែលត្រូវបានកែសម្រួល ឱ្យស្របតាមស្ថានភាពសិស្សដែលមានពិការភាព ដើម្បីបំពេញចន្លោះខ្វះខាតនៃការរៀនសូត្ររបស់ពួកគេ។ កុមារមានពិការភាពយ៉ាងហោចណាស់ ២៩,៩៣២ នាក់ (ស្រី ១២,៥៦២ នាក់) នឹងទទួលបានផលពីឯកសាររៀនសូត្រតាមផ្ទះចំនួន ៧៦០,០៤០ កញ្ចប់ ដែលបច្ចុប្បន្នកំពុងចែកជូនកុមាររៀនថ្នាក់ទី ១ និងថ្នាក់ទី ២ ទូទាំងប្រទេស ក៏ដូចជាសម្ភារៈអនាម័យ ដែលត្រូវបានចែកជូនសាលារដ្ឋទាំង ១៣,៤៨២ កន្លែងទូទាំងប្រទេស។
- អង្គការសហប្រជាជាតិបានផ្តល់ការគាំទ្រដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីកសាងប្រព័ន្ធកំណត់អត្តសញ្ញាណកម្មជនមានពិការភាព (ផ្អែកលើតម្រូវការសង្គម និងសិទ្ធិ) ដែលនេះជាប្រព័ន្ធទី ១ នៅកម្ពុជា ដើម្បីអាចកំណត់អត្តសញ្ញាណកុមារ និងជនមានពិការភាពទាំងអស់នៅក្នុងប្រទេស សំដៅជួយឱ្យពួកគេអាចទទួលបានសេវាគាំពារសង្គម សេវាថែទាំសង្គម និងឱកាសប្រកបមុខរបរចិញ្ចឹមជីវិត។ ជាលទ្ធផល ជនមានពិការភាពជាង ៦០,000 នាក់ ត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈប្រព័ន្ធកំណត់អត្តសញ្ញាណនេះ ដែលគេរំពឹងថានឹងបញ្ចប់រួចរាល់ទូទាំងប្រទេស នៅមុនបំណាច់ឆ្នាំ ២០២១។ ពាក់ព័ន្ធនឹងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ វិញ តាមរយៈកម្មវិធីដែលកំពុងអនុវត្តនៅក្នុងវិស័យចម្រុះជាមួយនឹងក្រសួងស្ថាប័នដទៃទៀតដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ អង្គការសហប្រជាជាតិ រួមនឹងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ បានសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងអង្គការតាមសហគមន៍ ដើម្បីជួយសម្រួល

ឱ្យក្រុមដែលងាយរងគ្រោះនៅក្នុងនោះមានទាំងជនដែលមានពិការភាពផងដែរ អាចទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ ១៩ ប្រកបដោយសមធម៌។ ឃុំចំនួន ៨០% (ពោលគឺ ១,៣២២ លើ ១,៦៤៦ ឃុំ) បានប្រមូលទិន្នន័យអំពីជនមានពិការភាព ដើម្បីរៀបចំផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ ជូនពួកគេ។ ជនមានពិការភាពចំនួន ១២៥,២១៧ នាក់ ត្រូវបានកំណត់អត្តសញ្ញាណ ក្នុងនោះ ៨៦,៤៧៩ នាក់ (ស្មើនឹង ៦៩%) បានទទួលការចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត។ ជនមានពិការភាព ១៧,៤៣៤ នាក់ លើ ៨៦,៤៧៩ នាក់ បានទទួលការចាក់វ៉ាក់សាំងគ្រប់ដូស។

- អង្គការសហប្រជាជាតិបានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋាភិបាល ដើម្បីលើកកម្ពស់បរិយាបន្នសង្គមសម្រាប់ស្ត្រី និងយុវជនមានពិការភាព ដើម្បីឱ្យពួកគេអាចទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ផ្តល់ព័ត៌មាន និងការអប់រំសម្រាប់ជនមានពិការភាព ដូចជាការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រជាដើម។

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមមួយចំនួននៅតែបន្តមាន ដូចជា ការបញ្ជ្រាបពិការភាពទៅក្នុងគោលនយោបាយ និងផែនការធំៗ ជាដើម។ នៅមានការងារជាច្រើនទៀតដែលចាំបាច់ត្រូវធ្វើ ដើម្បីកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាដទៃទៀត និងវិស័យឯកជន ដើម្បីធានាឱ្យមានការបញ្ចូលពិការភាពប្រកបដោយប្រសិទ្ធភាព ទៅក្នុងគ្រប់វិធានការឆ្លើយតបទាំងអស់ ចំពោះការរាតត្បាតជាសកល រួមទាំងក្នុងការតាក់តែង និងការអនុវត្តច្បាប់ គោលនយោបាយ និងផែនការផងដែរ។

អង្គការសហប្រជាជាតិខិតខំពង្រឹងសមត្ថភាព អ្នកផ្តល់សេវានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាមូលដ្ឋានប្រកបដោយសមធម៌ និងបង្កភាពងាយស្រួលដល់ជនមានពិការភាពរាប់បញ្ចូល ទាំងក្នុងអំឡុងពេលដែលមានស្ថានភាពអាសន្នផងដែរ។ សេវាទាំងនេះ មានដូចជា សេវាថែទាំសុខភាព សុខមាលភាពសង្គម ការស្តារលទ្ធភាពពលកម្ម សេវាស្វែងរកការងារឱ្យធ្វើ សេវាយុត្តិធម៌ និងសេវាអប់រំ និងការការពារក្រុមដែលងាយរងគ្រោះ រាប់បញ្ចូលទាំងក្រុមដែលមានពិការភាពផងដែរ។ ផែនការស្តារឡើងវិញរយៈពេល ៣ ឆ្នាំ សម្រាប់ជនមានពិការភាព អាចបំពេញតួនាទីជាផែនទីបង្ហាញផ្លូវនៅក្នុងន័យនេះ។

**ដើម្បីធានាសិទ្ធិ និងសុខមាលភាពរបស់ជនមានពិការភាព និងការទទួលបានសេវា និងការគាំទ្រនានា ទាមទារឱ្យមានការប្តេជ្ញាចិត្ត និងភាពច្នៃប្រឌិតពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់** ជាអាទិ៍ស្ថាប័នរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ ក្នុងពេលជាមួយគ្នាចាំបាច់ត្រូវមានការយកចិត្តទុកដាក់ជាបន្ទាន់ ដើម្បីធានាយ៉ាងណាឱ្យមានសមត្ថភាពឆ្លើយតបចំពោះសិទ្ធិ និងតម្រូវការជនមានពិការភាពគ្រប់ប្រភេទទាំងអស់ ដើម្បីជួយឱ្យពួកគេងាយស្រួលទទួលបានសេវា និងការគាំទ្រក្នុងសហគមន៍របស់ពួកគេផ្ទាល់ ឬនៅជិតសហគមន៍របស់ពួកគេ។

**អ្វីដែលសំខាន់ជាងគេនោះ ជនមានពិការភាពត្រូវតែជាចំណុចស្នូលនៃផែនការស្តារឡើងវិញ។ ពុំមាននរណាដឹងច្បាស់ជាងជនមានពិការភាពអំពីបញ្ហាប្រឈម និងឧបសគ្គ ដែលត្រូវជម្នះ ក្នុងដំណើរការស្តារឡើងវិញ**ពីការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ការស្តារឡើងវិញនូវសុខមាលភាព ក៏ដូចជាការទទួលបានសិទ្ធិ និងសេវាកម្ម ការគាំទ្រ និងឱកាសនានា ប្រកបដោយសមភាពជាមួយនឹងអ្នកដទៃ នោះឡើយ។

###

ឯកសារព័ត៌មានស្ដីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។